**សលាកប័ត្រព័ត៌មាន** ៖ កែល ភារុណ រងការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ព្រោះអត្ថបទលើហ្វេសប៊ុក
**ពេលវេលា** ៖ ខែមករា ឆ្នាំ២០១៣ មកទល់បច្ចុប្បន្ន
**រូបភាពរួម** ៖ គ្រូបង្រៀនម្នាក់ដែលម៉ូតូថ្មីមួយគ្រឿងរបស់គាត់ ត្រូវបាននគរបាលរាជធានីភ្នំពេញឃាត់ទុក ហើយគាត់ក៏ត្រូវបានកោះហៅដើម្បីសាកសួរពីបទបរិហារកេរ្តិ៍ បន្ទាប់ពីបានផ្សព្វផ្សាយព័ត៌មានលម្អិតស្តីពីព្រឹត្តិការណ៍នោះនៅលើហ្វេសប៊ុកផ្ទាល់ខ្លួន។ នេះជាករណីលើកដំបូងនៃករណីបែបនេះ នៅក្នុងព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”)។

## សេចក្តីផ្តើម

សលាកប័ត្រព័ត៌មាននេះ បង្ហាញពីការចោទប្រកាន់របស់នគរបាលរាជធានីភ្នំពេញ មកលើ លោក កែល ភារុណ ដែល អះអាងថាអត្ថបទរបស់ កែល ភារុណ នៅលើ ហ្វេសប៊ុក កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ ជាការបរិហារកេរ្តិ៍។ អត្ថបទដែលបានលើកឡើងនេះ គឺជាព័ត៌មានលម្អិតស្តីពីការឃាត់ម៉ូតូរបស់ កែល ភារុណ កាលពីល្ងាចថ្ងៃទី២៤ ខែមករា នោះ។ សលាកប័ត្រព័ត៌មាននេះសរសេរឡើងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ជាអង្គការមិនមែនរដ្ឋាភិបាលឯករាជ្យ និង មិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅទូទាំងប្រទេសកម្ពុជា។

## សាវតារ

កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ គ្រូបង្រៀនម្នាក់ឈ្មោះ កែល ភារុណ បានជិះម៉ូតូថ្មីរបស់ខ្លួន ដើម្បីយកទៅបិទស្កុត ជាវិធីពេញនិយមក្នុងការការពារឆ្នូត ពេលនោះនគរបាលពីរនាក់បានបញ្ឈប់ដំណើររបស់គាត់ នៅត្រង់ចំណុចវត្តមហាមន្ត្រី នៅកណ្តាលរាជធានីភ្នំពេញ ដោយសារតែម៉ូតូគ្មានផ្លាកលេខ គាត់បានប្រាប់ថានេះជាម៉ូតូថ្មីដូច្នេះ គាត់មិនទាន់មានពេលដើម្បីទៅចាប់ផ្លាកលេខនៅឡើយ។ បន្ទាប់មកមន្ត្រីនគរបាលនោះបានសុំឲ្យ កែល ភារុណ បង្ហាញឯកសារបញ្ជាក់ថាគាត់ពិតជាម្ចាស់ម៉ូតូនេះត្រឹមត្រូវតាមច្បាប់ ប៉ុន្តែគាត់មិនបានដាក់ឯកសារបញ្ជាក់កម្មសិទ្ធិជាប់ខ្លួន តែគាត់បានប្រាប់ថាគាត់អាចឲ្យមិត្តភក្តិរបស់គាត់យកឯកសារទាំងនោះមកកាន់វត្តមហាមន្ត្រី។ មន្ត្រីនគរបាលនោះបដិសេធ និងតម្រូវឲ្យគាត់ជិះម៉ូតូនោះទៅកាន់ប៉ុស្តិ៍នគរបាលខណ្ឌចំការមន។

កែល ភារុណ បានឲ្យប្អូនប្រុសខ្លួនយកឯកសារដែលត្រឹមត្រូវមកឲ្យនៅប៉ុស្តិ៍នគរបាល ដែលមន្ត្រីនគរបាលបានពិនិត្យមើលថាជាឯកសារត្រឹមត្រូវ និងបង្ហាញថា កែល ភារុណគឺជាម្ចាស់ម៉ូតូស្របច្បាប់។ ប៉ុន្តែ មន្ត្រីនគរបាលបានប្រាប់ឲ្យ កែល ភារុណ ត្រលប់មកម្តងទៀតនៅម៉ោង ៩ព្រឹក ថ្ងៃស្អែក ដើម្បីយកម៉ូតូវិញ។ កែល ភារុណ សុំឲ្យនគរបាលប្រគល់ម៉ូតូជូនលោកវិញភ្លាមៗ ប៉ុន្តែនគរបាលនោះបានបដិសេធ ដោយនិយាយថា ៖ “ម៉ូតូគង់តែឲ្យទេ គ្រាន់តែចាំថ្ងៃស្អែក” ។ ដោយមានការស្ទាក់ស្ទើរ កែល ភារុណ យល់ព្រមត្រលប់មកវិញនៅថ្ងៃស្អែក ប៉ុន្តែទទូចថានគរបាលសរសេរលិខិតធានាដើម្បីជាភស្តុតាងថាម៉ូតូរបស់លោកពិតជាត្រូវបានឃាត់ទុកនៅក្នុងប៉ុស្តិ៍នគរបាលពិតមែន។

នៅពេលត្រលប់មកផ្ទះ កែល ភារុណ បានសរសេររៀបរាប់លម្អិតពីព្រឹត្តិការណ៍នេះនៅលើហ្វេសប៊ុក បង្ហាញពីការព្រួយបារម្ភចំពោះទង្វើរបស់នគេបាលដែលបានធ្វើចំពោះរូបលោក។ អត្ថបទនៅលើហ្វេសប៊ុកបានសួរទៅកាន់អ្នកអានថា តើពួកគេគិតថាមានវិធីណាដែលអាចជួយធ្វើឲ្យនីតិវិធីរបស់នគរបាលមានភាពប្រសើរឡើង ដើម្បីជួយសម្រួលដល់ពលរដ្ឋដែលគោរពច្បាប់ដូចជារូបលោកនេះ។ គាត់ក៏បានផ្សាយរូបថតនៃលិខិតធានានៅលើហ្វេសប៊ុកផងដែរ។

នៅថ្ងៃទី២៦ ខែមករា វេបសាយព័ត៌មាន ដែលមានឈ្មោះថា សប្បាយ បានផ្សាយពីករណី របស់ កែល ភារុណ រួមជាមួយនឹងអត្ថបទនៅលើហ្វេសប៊ុករបស់គាត់ទាំងស្រុងផងដែរ។ អត្ថបទនេះបានបញ្ចូលនូវសម្តីរបស់ នាយការិយាល័យ

នគរបាលចរាចរណ៍ជើងគោក ដែលនិយាយថានគរបាលកំពុងតែអនុវត្តតាមច្បាប់ ដែលហាមឃាត់មិនឲ្យមានម៉ូតូដែលគ្មានផ្លាកលេខអាចធ្វើចរាចរណ៍បាននៅលើផ្លូវសាធារណៈ។

រយៈពេល មួយខែក្រោយ នាថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៣ កែល ភារុណ បានទទួលនូវលិខិតមួយពីមន្ត្រីនគរបាលសំណូមពរឲ្យគាត់ទៅប៉ុស្តិ៍នគរបាលនៅម៉ោង៨ព្រឹក នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៣ ដើម្បីឆ្លើយបំភ្លឺពាក់ព័ន្ធនឹងករណីបរិហារកេរ្តិ៍។ កែល ភារុណ ក៏បានផ្សាយព័ត៌មាននេះនៅលើហ្វេសប៊ុក ដោយនិយាយថាគាត់ជឿជាក់ថាករណីបរិហារកេរ្តិ៍នេះគឺពាក់ព័ន្ធនឹងព្រឹត្តិការណ៍ការឃាត់ម៉ូតូកាលពីខែមករា និងការផ្សាយករណីនេះនៅលើហ្វេសប៊ុក។ ដោយសារតែថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៣ ជាថ្ងៃឈប់សម្រាក និងដោយសារតែមានការងាររវល់ កែល ភារុណ បានស្នើសុំថាគាត់នឹងមកបង្ហាញខ្លួននៅក្នុងប៉ុស្តិ៍នគរបាលនៅថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១៣ ជំនួសវិញ ដែលមន្ត្រីនគរបាលក៏បានយល់ព្រម។

## បទបរិហារកេរ្តិ៍ និង សិទ្ធិសេរីភាពបញ្ចេញមតិ

មាត្រា៣០៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានផ្តល់និយមន័យ បរិហាកេរ្តិ៍ទាំងមានភាពស្រពេចស្រពិលថា *"គ្រប់ការបំផ្លើស ឬទម្លាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយ ដែលនាំឲ្យប៉ះពាល់ដល់កិត្តិយស ឬកិត្តិសព្ទនៃបុគ្គល ឬស្ថាប័ន"* ។ ការបរិហារកេរ្តិ៍អាចជាផ្ទាល់មាត់ សរសេរ ឬសំឡេង នឹងត្រូវផ្តន្ទាទោសពី មួយសែនរៀល ទៅដប់លានរៀល (ចាប់ពី ២៥ ទៅ ២៥០០ ដុល្លារសហរដ្ឋអាមេរិក)។ សកម្មភាពរបស់ កែល ភារុណ ក្នុងការផ្សព្វផ្សាយព័ត៌មានដូចបានរៀបរាប់ខាងលើ នៅលើហ្វេសប៊ុក មិនអាចចាត់ទុកថាជាការបរិហារកេរ្តិ៍នោះទេ ដោយសារតែការផ្សាយនោះមិនមែនដោយ "អសុទ្ធចិត្ត" ឬបើនិយាយមួយបែបទៀតគឺ កែល ភារុណ មិនបានផ្សព្វផ្សាយពីព័ត៌មានមិនពិត ប៉ុន្តែគ្រាន់តែរំលឹកឡើងវិញពីការប្រឈមមុខរបស់លោកជាមួយនឹងនគរបាល។ គាត់មិនបានសរសេរដើម្បីបំផ្លាញនូវកេរ្តិ៍ឈ្មោះរបស់នគរបាល ប៉ុន្តែគាត់គ្រាន់តែអនុវត្តសិទ្ធិសេរីភាពបញ្ចេញមតិរបស់លោក ក្នុងការចែករំលែកបទពិសោធន៍ និងដើម្បីជំរុញឲ្យមានការយល់ដឹង និងការជជែកពិភាក្សាពីផ្នែកច្បាប់។

សេរីភាពបញ្ចេញមតិត្រូវបានការពារដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ មាត្រា៤១ ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ) បានធានាជាពិសេសលើ *"សេរីភាពខាងការបញ្ចេញមតិ សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពខាងការប្រជុំ"* ។ មាត្រា១៩ នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន) និងមាត្រា១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (ស.ប.ស.ស) លិខិតុបករណ៍ទាំងពីរនេះបានធានាសិទ្ធិសេរីភាពបញ្ចេញមតិផងដែរ។ មាត្រា៣១ ក្នុងរដ្ឋធម្មនុញ្ញ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ កាលពីឆ្នាំ២០០៧ បានធានាថាទាំង ក.អ.ស.ព.ន និងស.ប.ស.ស ត្រូវបានបញ្ចូលក្នុងច្បាប់ជាតិរបស់កម្ពុជា។ ការការពារការបញ្ចេញមតិដោយសេរី ក៏បានពង្រីកវិសាលភាពទៅលើការបញ្ចេញមតិលើប្រព័ន្ធអ៊ីនធើណែតផងដែរ កាលពីខែកក្កដា ឆ្នាំ២០១២ ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ បានអនុម័តសេចក្តីសម្រេចមួយដែលធានាថា *"សិទ្ធិដូចគ្នាដែលប្រជាពលរដ្ឋមាននៅក្រៅប្រព័ន្ធអ៊ីនធើណែត ក៏គួរតែត្រូវបានការពារនៅលើប្រព័ន្ធអ៊ីនធើណែតផងដែរ ជាពិសេស សេរីភាពបញ្ចេញមតិ ដែលអាចអនុវត្តបានដោយមិនគិតពីព្រំដែន និងតាមរយៈមធ្យោបាយផ្សព្វផ្សាយដទៃតាមការជ្រើសរើសរបស់ខ្លួន"* ។

ដូច្នេះ ការផ្សព្វផ្សាយនូវព័ត៌មានខាងលើអំពីការប្រឈមមុខរបស់ កែល ភារុណ ជាមួយនគរបាល គឺគ្រាន់តែជាការអនុវត្តន៍សិទ្ធិសេរីភាពបញ្ចេញមតិរបស់គាត់នៅលើប្រព័ន្ធអ៊ីនធើណែតតែប៉ុណ្ណោះ។ សិទ្ធិសេរីភាពបញ្ចេញមតិ មានការដាក់កំហិតមួយចំនួន រាប់បញ្ចូលទាំងការគោរពកិត្តិយសរបស់អ្នកដទៃផងដែរ។ ប៉ុន្តែ សេចក្តីពន្យល់ទូទៅលេខ៣៤ របស់

គណៈកម្មាធិការសិទ្ធិមនុស្ស (ជាស្ថាប័នពិនិត្យមើលការអនុវត្តន៍ការងាររបស់ ក.អ.ស.ព.ន) ដែលពន្យល់ពីកាតព្វកិច្ចរបស់រដ្ឋក្នុងមាត្រា១៩ បញ្ជាក់ថារដ្ឋភាគីនៃ ក.អ.ស.ព.ន *"គួរតែកុំហាមឃាត់ការរិះគន់លើស្ថាប័ន"* ។ សេចក្តីពន្យល់នេះថែមទាំងបានបញ្ជាក់ផងដែរ *"កតិកាសញ្ញានេះបានផ្តល់តម្លៃយ៉ាងខ្ពស់ជាពិសេស ដល់ការបញ្ចេញមតិដោយចំហ ក្នុងកាលៈទេសៈដែលមានការជជែកដេញដោលជាសាធារណៈ ទាក់ទងនឹងឥស្សរជនក្នុងជួរនយោបាយ និងក្នុងមុខងារសាធារណៈ"* ។ កែល ភារុណ មិនបានរិះគន់ដល់នគរបាល ឬស្ថាប័នសាធារណៈ តាមរយៈហ្វេសប៊ុកនោះទេ ហើយបើទោះបីជាលោកបានធ្វើបែបនោះមែន នោះគឺគ្រាន់តែជាការអនុវត្តន៍សិទ្ធិរបស់គាត់ទាំងស្រុង។

បទបរិហារកេរ្តិ៍ដែលចែងដោយស្រពេចស្រពិល ដែលត្រូវបានប្រើប្រាស់ជាញឹកញាប់នៅកម្ពុជាដើម្បីបំបិទសំឡេងប្រឆាំង គឺមិនអនុលោមទៅនឹងកាតព្វកិច្ចរបស់កម្ពុជា ដែលចែងក្នុងរដ្ឋធម្មនុញ្ញ និងនៅក្នុង ក.អ.ស.ព.ន។ ដើម្បីឆ្លើយតបទៅនឹងគំនាបរបស់សហគមន៍អន្តរជាតិ ក្នុងខែឧសភា ឆ្នាំ២០០៦ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសន្យាថាលោកនឹងដកបទបរិហារកេរ្តិ៍ចេញពីបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែរយៈពេលជិតប្រាំពីរឆ្នាំមកហើយ បទបរិហារកេរ្តិ៍នៅតែស្ថិតក្នុងបទល្មើសព្រហ្មទណ្ឌ។ គួរបញ្ជាក់ផងដែរថា ទោះបីជាបទបរិហារកេរ្តិ៍មិនមានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ ប៉ុន្តែការមិនព្រមបង់ប្រាក់ពិន័យនៅតែជាបទល្មើសដែលអាចប្រឈមនឹងការជាប់ពន្ធនាគារ។

ករណីរបស់ កែល ភារុណ គឺជាករណីលើកទីមួយ ដែលពលរដ្ឋកម្ពុជាអាចប្រឈមមុខនឹងការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ដោយសារតែការអនុវត្តន៍សិទ្ធិសេរីភាពបញ្ចេញមតិរបស់ខ្លួនពាក់ព័ន្ធនឹងអាជ្ញាធរ នៅលើហ្វេសប៊ុក។

**សេចក្តីសន្និដ្ឋាន/អនុសាសន៍**

កែល ភារុណ មានសិទ្ធិសេរីភាពបញ្ចេញមតិរបស់ខ្លួនដោយសេរី ហើយសកម្មភាពរបស់គាត់ក្នុងការធ្វើបែបនេះមិនអាចត្រូវបានចាត់ទុកថាជាការបរិហារកេរ្តិ៍នោះទេ។ អវត្តមាននៃផលប្រយោជន៍សាធារណៈដែលកើតមានពីការរឹតត្បិតសេរីភាពបញ្ចេញមតិនៅលើប្រព័ន្ធអ៊ីនធើណែត ការប៉ុនប៉ងនានារបស់នគរបាលក្នុងការគំរាម ឬផ្តន្ទាទោស កែល ភារុណ ដោយសារតែគាត់បានបញ្ចេញមតិដោយសេរី គឺជាការរំលោភបំពានយ៉ាងច្បាស់មកលើសិទ្ធិសេរីភាពមូលដ្ឋាន របស់ កែល ភារុណ។

នគរបាលរាជធានីភ្នំពេញ គួរតែបញ្ឈប់នូវការប៉ុនប៉ងគំរាមមកលើ កែល ភារុណ និងបញ្ឈប់នូវការប៉ុនប៉ងនានាក្នុងការរឹតត្បិតសិទ្ធិសេរីភាពបញ្ចេញមតិតាមរយៈការអះអាងថាជាបទបរិហារកេរ្តិ៍។ មិនតែប៉ុណ្ណោះ រដ្ឋាភិបាលកម្ពុជា គួរតែធ្វើចាត់វិធានការជាបន្ទាន់ ដើម្បីធានាថាមន្ត្រីនគរបាលកម្ពុជាទាំងអស់យល់ពីចរិតលក្ខណៈ និងវិសាលភាពនៃសិទ្ធិរបស់ប្រជាពលរដ្ឋ ដើម្បីការពារមិនឲ្យមានករណីគំរាមកំហែងបែបនេះកើតឡើងនាពេលអនាគត។

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង ៖ កញ្ញា សន រ៉ាមណា តាមរយៈទូរសព្ទលេខ ០១៧ ៦៥ ៥៥ ៩១ ឬអ៊ីម៉ែល ៖** ramansorn@cchrcambodia.org **ឬ កញ្ញា អូឡា ខេលី តាមរយៈទូរសព្ទលេខ ០៦៧ ៧២ ៧០ ២៥ ឬអ៊ីម៉ែល ៖** orla.kelly@cchrcambodia.org ។